**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ ៥១ អនក្រ.សសរ**

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំពិធីអបអរសាទរការបញ្ចូល "តំបន់ប្រាសាទសំបូរព្រៃគុក" ក្នុងបញ្ជីបេតិកភណ្ឌពិភពលោក

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
-យោងសេចក្តីសម្រេច DECISION 41 COM 8B.15 ថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០១៧ ដែលបានសម្រេចចុះ "តំបន់ប្រាសាទសំបូរព្រៃគុក " ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក
-យោងតាមការចាំបាច់ ។

## សម្រេច

**ប្រការ ១៖** ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំពិធីអបអរសាទរ ការបញ្ចូល "តំបន់ប្រាសាទសំបូរព្រៃគុក" ក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ដែលមានសមាសភាពដូចខាងក្រោម៖



www.pheakdeylaw.com

| | | |
|---|---|---|
| ១. ឯកឧត្តម ប៊ិន ឈិន | ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២. លោកជំទាវ ភឿង សកុណា | រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៣. ឯកឧត្តម ថោង ខុន | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | អនុប្រធាន |
| ៤. ឯកឧត្តម ហង់ជួន ណារ៉ុន | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៥. ឯកឧត្តម សាយ សំអាល់ | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | អនុប្រធាន |
| ៦. ឯកឧត្តម ហ៊ុន ម៉ានី | ប្រធានស.ស.យ.ក | អនុប្រធាន |
| ៧. ឯកឧត្តម ឃួង ស្រេង | អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ | អនុប្រធាន |
| ៨. ឯកឧត្តម យឹម សារិទ្ធ | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធានអចិន្ត្រៃយ៍ |
| ៩. ឯកឧត្តម គឹកម៉េត សំរេច | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ១០. លោកជំទាវ ហ៊ុន ម៉ាណា | អគ្គនាយិកាវិទ្យុ និងទូរទស្សន៍បាយ័ន | អនុប្រធាន |
| ១១. ឯកឧត្តម ជូ វិជិត្ត | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១២. ឯកឧត្តម អ៊ុច បូរិទ្ធ | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៣. ឯកឧត្តម ព្រុំ សុខា | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១៤. ឯកឧត្តម តែ គុយសាង | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១៥. ឯកឧត្តម កើត រិទ្ធ | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ១៦. ឯកឧត្តម យូ ស៊ុនឡុង | រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | សមាជិក |
| ១៧. ឯ.ឧ នាយឧត្តមសេនីយ៍ ហ៊ុយ ពិសិដ្ឋ | អនុរដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ១៨. ឯកឧត្តម ឈិន កេតនា | អគ្គលេខាធិការគណៈកម្មាធិការរៀបចំបុណ្យជាតិ និងអន្តរជាតិ | សមាជិក |
| ១៩. ឯ.ឧ នាយឧត្តមសេនីយ៍ នេត សាវឿន | អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ២០. ឯ.ឧ នាយឧត្តមសេនីយ៍ សៅ សុខា | អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ២១. ឯ.ឧ នាយឧត្តមសេនីយ៍ ហ៊ីង ប៊ុនហៀង | អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការនៃបញ្ជាការដ្ឋានអង្គរក្ស | សមាជិក |

| | | |
|---|---|---|
| ២២. ឯ.ឧ នាយឧត្តមសេនីយ៍ ឌឹត សារ៉ាត់ | អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជានាយកទីចាត់ការហិរញ្ញវត្ថុ | សមាជិក |
| ២៣. ឯកឧត្តម សុខ លូ | អភិបាល នៃគណៈអភិបាលខេត្តកំពង់ធំ | សមាជិក |
| ២៤. ឯកឧត្តម មាន ចាន់យ៉ាដា | អភិបាលរងរាជធានីភ្នំពេញ | សមាជិក |
| ២៥. ឯកឧត្តម ឡុង ប៉ុណ្ណាស៊ីរីវុទ្ធ | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ២៦. ឯកឧត្តម ប្រាក់ សុណ្ណារ៉ា | អគ្គនាយកបេតិកភណ្ឌ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ២៧. ឯកឧត្តម ផាន់ ណារិទ្ធិ | អគ្គនាយកអាជ្ញាធរសំបូរព្រៃគុក ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ២៨. ឯកឧត្តម ទិត្យ ចាំរើន | ប្រធានក្រុមបច្ចេកទេសទូរទស្សន៍បាយ័ន | សមាជិក |

**ប្រការ ២** ៖ គណៈកម្មការអន្តរក្រសួងនេះមានតួនាទីដឹកនាំ និងសម្របសម្រួលរាល់ដំណើរការការងារ រៀបចំពិធីអបអរសាទរការបញ្ចូល "តំបន់ប្រាសាទសំបូរព្រៃគុក" ក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ដែលមានភារកិច្ចដូចខាងក្រោម៖

-ដឹកនាំ ចាត់ចែង ត្រួតពិនិត្យ សម្របសម្រួលជាមួយស្ថាប័ន និងអង្គភាពពាក់ព័ន្ធ

-រៀបចំខ្លឹមសារ ឯកសារ លិខិតបទដ្ឋានរដ្ឋបាល បដាពាក្យស្លោក និងបោះពុម្ពអាវសម្រាប់ពិធី

-រៀបចំគម្រោងចំណាយ នៃដំណើរការរៀបចំពិធី

-រៀបចំទម្រង់សិល្បៈ ទស្សនីយភាព និងការសម្តែងនានាក្នុងព្រឹត្តិការណ៍

-ការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសង្គ្រោះបន្ទាន់

-រៀបចំការពារសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់ ចរាចរ និងធានាសុវត្ថិភាពឲ្យបានគ្រប់គ្រាន់នៅមុន និងក្រោយពេលប្រារព្ធពិធី និងតាមផ្លូវឆ្លងកាត់

-ទំនាក់ទំនង និងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ស្ថាប័នពាក់ព័ន្ធក្នុងការអញ្ជើញភ្ញៀវជាតិ និងអន្តរជាតិចូលរួមក្នុងពិធី

**ប្រការ ៣** ៖ គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការ ឬក្រុមការងារបន្ថែមតាមការចាំបាច់ ដោយមានការយល់ព្រម ពីប្រធានគណៈកម្មការអន្តរក្រសួង។

**ប្រការ ៤** ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ អភិបាល នៃគណៈអភិបាលខេត្តកំពង់ធំ



www.pheakdeylaw.com

និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ ២០១៧
**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ សម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ ៤
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com